**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំសរុប ៤១១,៨៧ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចចំការដូងប្រេងក្រុមហ៊ុន ម៉ុង ឬទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជា កម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣០៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅភូមិតាពៅ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ២៣៣សណ/១២ចុះថ្ងៃទី១៦ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ដីសរុបទំហំ ៩១១,៨៧ **ហិកតា** (បួនរយដប់មួយហិកតា និងប៉ែតសិបប្រាំពីរអា) ចេញពីដីសម្បទានសេដ្ឋកិច្ចចំការដូងប្រេងរបស់ក្រុមហ៊ុនម៉ុងឬទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋស្ថិតនៅភូមិតាពៅ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ-I នៃអនុក្រឹត្យនេះ ។

**មាត្រា ២..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន៣០៥(បីរយប្រាំ)គ្រួសារដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិតាពៅ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចចែងក្នុងមាត្រា១ខាងលើ។

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ផែនទីឧបសម្ព័ន្ធទី....នៃអនុក្រឹត្យលេខ..២៤៧..អនក្រ.បក..ចុះថ្ងៃទី១១ខែ..ធ្នូ....ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំ ៤១១,៨៧ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ច ចំការដូងប្រេងក្រុមហ៊ុន ម៉ុង ឬទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣០៥គ្រួសារដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាពៅ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ (ក)




| តារាងនិយាមការចំនុចព្រំដីស្នើសុំ | | | តារាងនិយាមការចំនុចព្រំដីស្នើសុំ | | |
|---|---|---|---|---|---|
| វាស់វែងដោយឧបករណ៍ Garmin GPSMap 62s | | | វាស់វែងដោយឧបករណ៍ Garmin GPSMap 62s | | |
| Projection UTM, Zone 48N, Datum WGS 84 | | | Projection UTM, Zone 48N, Datum WGS 84 | | |
| ប្រភពទិន្នន័យ: ផែនទីឋានលេខា(Topomap) | | | ប្រភពទិន្នន័យ: ផែនទីឋានលេខា(Topomap) | | |
| Point_ID | EASTING | NORTHING | Point_ID | EASTING | NORTHING |
| 1 | 369725.108 | 1196577.477 | 20 | 370311.998 | 1196726.943 |
| 2 | 369761.454 | 1196576.188 | 21 | 370315.441 | 1196725.728 |
| 3 | 369775.433 | 1196576.253 | 22 | 370318.276 | 1196725.930 |
| 4 | 369780.927 | 1196576.279 | 23 | 370323.338 | 1196729.170 |
| 5 | 369781.889 | 1196583.172 | 24 | 370328.806 | 1196727.550 |
| 6 | 369821.008 | 1196821.748 | 25 | 370335.286 | 1196724.715 |
| 7 | 369821.211 | 1196823.001 | 26 | 370340.552 | 1196725.728 |
| 8 | 369848.461 | 1196818.070 | 27 | 370348.449 | 1196728.765 |
| 9 | 370061.093 | 1196779.594 | 28 | 370354.525 | 1196731.803 |
| 10 | 370240.514 | 1196745.978 | 29 | 370358.372 | 1196733.220 |
| 11 | 370247.399 | 1196741.321 | 30 | 370362.422 | 1196732.208 |
| 12 | 370257.726 | 1196742.940 | 31 | 370365.460 | 1196730.385 |
| 13 | 370268.662 | 1196735.245 | 32 | 370368.295 | 1196729.778 |
| 14 | 370272.712 | 1196735.853 | 33 | 370373.155 | 1196730.385 |
| 15 | 370279.800 | 1196734.233 | 34 | 370378.420 | 1196732.005 |
| 16 | 370287.697 | 1196732.005 | 35 | 370381.660 | 1196731.398 |
| 17 | 370293.570 | 1196729.373 | 36 | 370384.293 | 1196729.575 |
| 18 | 370298.430 | 1196728.765 | 37 | 370387.533 | 1196727.348 |
| 19 | 370305.518 | 1196727.550 | (ទំព័រ១/៥) សូមបន្តតារាងចំនុចនិយាមការនៅទំព័របន្ទាប់ | | |

ផែនទីឧបសម្ព័ន្ធទី....នៃអនុក្រឹត្យលេខ..២៤៩..អនក្រ.បក.ចុះថ្ងៃទី១៦ខែ..ធ្នូ..ឆ្នាំ២០១២ស្តីពីការកាត់ដីទំហំ ៤១១,៨៧ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ច ចំការដូងប្រេងក្រុមហ៊ុន ម៉ុង ឫទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣០៥គ្រួសារដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាពៅ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

តារាងនិយាមកានៃចំនុចព្រំដីស្នើសុំ (ទំព័រទី៥/៥)

| តារាងនិយាមកានៃចំនុចព្រំដីស្នើសុំ | | |
|---|---|---|
| វាស់វែងដោយឧបករណ៍ Garmin GPSMap 62s | | |
| Projection UTM, Zone 48N, Datum WGS 84 | | |
| Point_ID | EASTING | NORTHING |
| 728 | 364808.603 | 1197400.182 |
| 729 | 364808.609 | 1197400.195 |
| 730 | 364808.732 | 1197400.433 |
| 731 | 364809.214 | 1197401.367 |
| 732 | 364810.672 | 1197404.192 |
| 733 | 364813.125 | 1197408.947 |
| 734 | 364813.293 | 1197409.271 |
| 735 | 364813.609 | 1197409.884 |
| 736 | 364814.819 | 1197412.228 |
| 737 | 364833.940 | 1197449.279 |
| 738 | 364834.192 | 1197449.768 |
| 739 | 364834.249 | 1197449.878 |
| 740 | 364834.378 | 1197450.129 |
| 741 | 364834.741 | 1197450.833 |
| 742 | 364834.821 | 1197450.986 |
| 743 | 364836.491 | 1197454.224 |
| 744 | 364838.118 | 1197457.374 |
| 745 | 364878.500 | 1197535.625 |
| 746 | 364900.600 | 1197571.908 |
| 747 | 364924.286 | 1197610.794 |
| 748 | 364937.246 | 1197632.071 |
| 749 | 364947.938 | 1197649.625 |
| 750 | 364963.574 | 1197681.002 |
| 751 | 364966.233 | 1197686.339 |
| 752 | 364967.926 | 1197689.735 |
| 753 | 364970.025 | 1197693.947 |
| 754 | 364981.573 | 1197717.120 |
| 755 | 365023.187 | 1197800.625 |
| 756 | 365068.322 | 1197900.159 |
| 757 | 365078.944 | 1197894.927 |
| 758 | 365141.428 | 1197854.971 |
| 759 | 365159.863 | 1197817.515 |
| 760 | 365168.033 | 1197812.217 |
| 761 | 365168.746 | 1197811.755 |
| 762 | 365169.055 | 1197811.555 |
| 763 | 365177.259 | 1197806.236 |
| 764 | 365221.135 | 1197783.523 |
| 765 | 365256.426 | 1197782.009 |
| 766 | 365263.353 | 1197781.712 |
| 767 | 365268.711 | 1197781.483 |
| 768 | 365271.599 | 1197781.359 |
| 769 | 365276.218 | 1197781.161 |
| 770 | 365305.483 | 1197779.906 |
| 771 | 365350.191 | 1197777.988 |
| 772 | 365360.002 | 1197729.687 |
| 773 | 365369.058 | 1197676.857 |
| 774 | 365383.051 | 1197578.369 |
| 775 | 365384.721 | 1197576.122 |
| 776 | 365388.670 | 1197570.809 |
| 777 | 365389.996 | 1197569.024 |
| 778 | 365404.881 | 1197548.995 |
| 779 | 365405.919 | 1197543.737 |
| 780 | 365406.756 | 1197539.498 |
| 781 | 365408.072 | 1197532.836 |
| 782 | 365413.559 | 1197505.054 |
| 783 | 365456.845 | 1197475.792 |
| 784 | 365459.865 | 1197471.477 |
| 785 | 365464.841 | 1197464.366 |
| 786 | 365466.158 | 1197462.485 |
| 787 | 365467.087 | 1197461.157 |
| 788 | 365481.225 | 1197440.954 |
| 789 | 365488.063 | 1197431.184 |
| 790 | 365495.652 | 1197420.338 |
| 791 | 365495.928 | 1197419.477 |
| 792 | 365496.228 | 1197418.540 |
| 793 | 365496.572 | 1197417.464 |
| 794 | 365496.762 | 1197416.870 |
| 795 | 365502.671 | 1197398.412 |
| 796 | 365475.445 | 1197370.873 |
| 797 | 365472.536 | 1197354.296 |
| 798 | 365476.148 | 1197336.128 |